# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ៧ ធ្នូ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 11-Dec-2012, 08:30
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ អៀង សារី ស្នើសុំព័ត៌មានពាក់ព័ន្ធនឹងអ្នកជំនាញដែលមានលេខសម្គាល់ TCE-33**

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្ដី អៀង សារី**

អាង ឧត្តម

Michael G. KARNAVAS

**ចម្លងជូន:**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន**

ចៅក្រម **យ៉ុយ ឧត្តរា**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **ធូ មន្នី**

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

## I. សេចក្ដីផ្ដើម

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្ដី”) សូមស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ទទួល និងផ្ដល់ព័ត៌មានទៅភាគីពាក់ព័ន្ធប្រវត្តិ និងសកម្មភាពវិជ្ជាជីវៈរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 មុនពេលគាត់បង្ហាញខ្លួននៅតុលាការ។ សំណើនេះមានភាពចាំបាច់ដោយសារសេចក្ដីសម្រេចកាលពីពេលថ្មីៗរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីកោះហៅអ្នកជំនាញដែលមានរហស្សនាម TCE-33 ក្នុងនាមជាសាក្សីមួយរូប ក្នុងសំណុំរឿង ០០២/០១[1] បើទោះបីជាពុំមានលទ្ធភាពដែលថាអ្នកជំនាញដែលមានរហស្សនាម TCE-33 អាចជាសាក្សីប្រកបដោយឯករាជ្យ និងពុំលម្អៀងក៏ដោយ។ លក្ខណៈនៃសកម្មភាពវិជ្ជាជីវៈរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 និងទំនាក់ទំនងរយៈពេលយូររបស់គាត់ជាមួយការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត នៅ អ.វ.ត.ក ប៉ះពាល់ដល់ភាពអាចជឿជាក់បានរបស់គាត់ក្នុងនាមជាសាក្សីដែលពុំលម្អៀង។ អង្គជំនុំជម្រះសាលាដំបូងត្រូវតែទទួលបានពីអ្នកជំនាញដែលមានរហស្សនាម TCE-33 នូវព័ត៌មានបន្ថែមទៀតអំពីប្រវត្តិ និងសកម្មភាពវិជ្ជាជីវៈរបស់គាត់ មុនពេលគាត់ផ្ដល់សក្ខីកម្ម។

## I. សាវតារ

១. កាលពីថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយដោយបានគូសបញ្ជាក់ថាអង្គជំនុំជម្រះនឹងកោះហៅអ្នកជំនាញដែលមានរហស្សនាម TCE-33 ដើម្បីផ្ដល់សក្ខីកម្ម “ដោយពិនិត្យទៅលើឯកសារជាច្រើននៅក្នុងសំណុំរឿង និងឯកសារដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដែលគាត់បានដឹងផ្ទាល់ និង/ឬ គាត់ជាអ្នកនិពន្ធ”[2]។ អង្គជំនុំជម្រះសាលាដំបូងពុំបានគូសបញ្ជាក់ថាតើអ្នកជំនាញដែលមានរហស្សនាម TCE-33 នឹងផ្ដល់សក្ខីកម្មក្នុងនាមជាសាក្សីអ្នកជំនាញ ដែរឬយ៉ាងណាឡើយ[3]។

---

[1] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា ការប្រកាសអំពីសាក្សីដែលគ្រោងផ្ដល់សក្ខីកម្មនាពេលខាងមុខ, ថ្ងៃទី ២៦ ខែ វិច្ឆិកា, ឯកសារ E236/2, ទំព័រ ១។

[2] *ដូចឯកសារយោងខាងលើ,* ទំព័រ ១។

[3] មេធាវីការពារក្ដីបានជំទាស់ម្ដងហើយម្ដងទៀតទៅនឹងការតែងតាំងអ្នកជំនាញដែលមានរហស្សនាម TCE-33 ជាសាក្សីអ្នកជំនាញ។ *សូមមើល ជាឧទាហរណ៍* ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលដាក់អមជាមួយនឹងបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០, ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារ E9/4/1។ ការជំទាស់ជាបឋមរបស់លោក អៀង សារី ចំពោះសំណើសុំអ្នកជំនាញរបស់ ក.ស.ព និងសំណើសុំការអនុញ្ញាតដាក់សារណាបន្ថែមទៀតក្នុងរយៈពេល ៣០ ថ្ងៃ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារ E9/4/9។ សេចក្ដីសង្ខេបរួមរបស់លោក

២. កាលពីឆ្នាំ ២០០៤ ដែលជាអំឡុងពេលនៃការបង្កើត អ.វ.ត.ក និងនៅមុនពេលមានកិច្ចស៊ើបសួរបឋមរបស់ ក.ស.ព អ្នកជំនាញដែលមានរហស្សនាម TCE-33 បានរួមនិពន្ធសៀវភៅមួយក្បាលដែលមានចំណងជើងថា បេក្ខជនចំនួនប្រាំពីររូបសម្រាប់ការចោទប្រកាន់៖ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហម (Seven Candidates for Prosecution: Accountability for the Crimes of the Khmer Rouge)។ លោក អៀង សារី គឺជាបេក្ខជនមួយរូបក្នុងចំណោម "បេក្ខជនចំនួន ៧ រូបសម្រាប់ការចោទប្រកាន់" ដែលអ្នកជំនាញដែលមានរហស្សនាម TCE-33 បានបង្ហាញឈ្មោះ[4]។

៣. ចាប់ពីខែ កក្កដា ឆ្នាំ ២០០៦ ដល់ខែ ធ្នូ ឆ្នាំ ២០០៦ មុនពេលមានការដាក់សេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[5] អ្នកជំនាញដែលមានរហស្សនាម TCE-33 បានបម្រើការងារជាអ្នកវិភាគសម្រាប់ ក.ស.ព[6]។ កាលពីពេលនោះ ក.ស.ព បានកំពុងស៊ើបអង្កេតបេក្ខជនយ៉ាងហោចណាស់

---

អៀង សារី ស្ដីពីសាក្សី និងអ្នកជំនាញមួយចំនួនដែលសហព្រះរាជអាជ្ញា ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីការពារក្ដី នួន ជា បានស្នើសុំកោះហៅបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញបញ្ជីឈ្មោះសាក្សីបណ្ដោះអាសន្ន, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ E93/12។ ចម្លើយតបរបស់លោក អៀង សារី អនុលោមតាមវិធាន ៨៧(៤) ទៅនឹងសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា សុំកោះហៅសាក្សី TCW-505, TCW-754, TCW-100, TCE-33, TCW-720, TCW-781 និងសាក្សី TCW-164, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារ E218/3/1។ អង្គជំនុំជម្រះសាលាដំបូងពុំបានដាក់បញ្ចូលអ្នកជំនាញដែលមានរហស្សនាម TCE-33 នៅក្នុងសេចក្ដីប្រគល់ឋានៈជាសាក្សីអ្នកជំនាញ ទៅអ្នកជំនាញមួយចំនួនដែលត្រូវបានសុំឡើយ។ *សូមមើល* សេចក្ដីសម្រេចលើការចាត់តាំងអ្នកជំនាញ, ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១២, ឯកសារ E215។

[4] Stephen Heder & Brian Tittemore, បេក្ខជនចំនួនប្រាំពីររូបសម្រាប់ការចោទប្រកាន់៖ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហម (Seven Candidates for Prosecution: Accountability for the Crimes of the Khmer Rouge) ទំព័រ ៧៥-៩២ (ខែ មីនា ឆ្នាំ ២០០៤), ឯកសារ E3/48។ កាលដើមឡើយ របាយការណ៍នេះត្រូវបានបោះពុម្ពផ្សាយ ក្នុងខែ មិថុនា ឆ្នាំ ២០០១ តាមរយៈការិយាល័យស្រាវជ្រាវឧក្រិដ្ឋកម្មសង្គ្រាម (War Crimes Research Office) មហាវិទ្យាល័យច្បាប់វ៉ាស៊ីងតោន (Washington College of Law), សាកលវិទ្យាល័យអាមេរិក (American University)។ របាយការណ៍នេះក្នុងសំណៅឆ្នាំ ២០០៤ ត្រូវបានបោះពុម្ពផ្សាយដោយមានកិច្ចសហការជាមួយ មជ្ឈមណ្ឌលឯកសារកម្ពុជា។

[5] សេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧, ឯកសារ D3។

[6] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យស្ដាប់អ្នកជំនាញ ២ រូប និងសាក្សី ១៣ រូបបន្ថែមនៅក្នុងដំណាក់កាលដំបូងសវនាការ និងការជូនដំណឹងអំពីចេតនាដាក់ឈុតវីដេអូខ្លីៗចំនួន ៧ ទាក់ទងទៅនឹង នួន ជា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមវិធាន ៨៧(៤), ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ E93/7, កថាខណ្ឌ ៩។ សំណើសុំព័ត៌មានទាក់ទងនឹងទំនាស់ផលប្រយោជន៍ដ៏មានសក្ដានុពល, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨, ឯកសារ A121។ លិខិតរបស់ ក.ស.ច.ស ទៅមេធាវីការពារក្ដីដែលមានចំណងជើងថា សំណើសុំផ្ដល់ព័ត៌មានទាក់ទិននឹងករណីទំនាស់ផលប្រយោជន៍ជាយថាហេតុ, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៨ ("លិខិតរបស់ ក.ស.ច.ស កាលពីឆ្នាំ ២០០៨ ផ្ញើទៅមេធាវីការពារក្ដី"), ឯកសារ A121/I, ទំព័រ ១។

ចំនួន ៣ រូប ក្នុងចំណោម "បេក្ខជនសម្រាប់ការចោទប្រកាន់" ចំនួន ៧ រូបដែល អ្នកជំនាញដែលមានរហស្សនាម TCE-33 បានកំណត់អត្តសញ្ញាណកាលពី ២ ឆ្នាំមុន។

៤. ក្នុងខែ ធ្នូ ឆ្នាំ ២០០៦ អ្នកជំនាញដែលមានរហស្សនាម TCE-33 បានផ្ទេរទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ដើម្បីបម្រើការងារជាអ្នកស៊ើបអង្កេត[7] ដោយបានជួយដល់កិច្ចស៊ើបសួរ និងការរៀបចំដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរតែអង្គហេតុណា ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ ក.ស.ព[8]។ អ្នកជំនាញដែលមានរហស្សនាម TCE-33 បានបន្តស្ថិតនៅជាមួយ ក.ស.ច.ស រហូតដល់យ៉ាងហោចណាស់ត្រឹមថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១០[9]។

៥. យោងតាមការរៀបរាប់របស់សាក្សីផ្ទាល់ភ្នែកគឺលោក Wayne Bastin ដែលជាអតីតប្រធានអង្គភាពស៊ើបការណ៍សម្ងាត់ និងវិភាគនៃ ក.ស.ច.ស[10] នៅពេលដែលលោកកំពុងបម្រើការងារជូនការិយាល័យ ក.ស.ច.ស អ្នកជំនាញដែលមានរហស្សនាម TCE-33 បានចូលរួមកិច្ចប្រជុំមួយរវាងចៅក្រម Lemonde និងសមាជិកអន្តរជាតិមួយចំនួននៃ ក.ស.ច.ស នៅឯគេហដ្ឋានរបស់ចៅក្រម Lemonde នៅទីក្រុងភ្នំពេញ។ នៅក្នុងកិច្ចប្រជុំនេះ ចៅក្រម Lemonde បានណែនាំឲ្យ អ្នកជំនាញដែលមានរហស្សនាម TCE-33 និងបុគ្គលដទៃទៀត ដែលមានវត្តមាន ស្វែងរកជាសំខាន់នូវភស្តុតាងដាក់បន្ទុក ជាជាងបំពេញកិច្ចស៊ើបសួរមួយដែលពុំលម្អៀង។ ចៅក្រម Lemonde បានគូសបញ្ជាក់ថា គាត់ឲ្យក្រុមនេះ "ស្វែងរកភស្តុតាងដាក់បន្ទុក ឲ្យបានច្រើនជាងភស្តុតាងដោះ

---

[7] លិខិតរបស់ ក.ស.ច.ស កាលពីឆ្នាំ ២០០៨ ផ្ញើទៅមេធាវីការពារក្តី, ទំព័រ ១។

[8] វិធាន ៥៥(២)។

[9] *សូមមើល* ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំចាត់តាំងអ្នកជំនាញ, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១០, ឯកសារ D281/3, កថាខណ្ឌ ៧។

[10] ជំនាញវិជ្ជាជីវៈរបស់លោក Bastin គឺមិនអាចប្រកែកបានឡើយ។ នាពេលបច្ចុប្បន្ន គាត់បម្រើការងារជាមន្ត្រីនគរបាលនៅអូស្ត្រាលី។ គាត់បម្រើការងារអស់រយៈពេលចំនួន ៣១ ឆ្នាំ ភាគច្រើននៅតាមតំបន់ដែលមានឧក្រិដ្ឋកម្ម និងអំពើមនុស្សឃាតដែលត្រូវបានរៀបចំ ដែលតួនាទីចម្បងរបស់គាត់គឺជាអ្នកគ្រប់គ្រងផ្នែកស៊ើបការណ៍សម្ងាត់។ គាត់ធ្លាប់បានបម្រើការងារអស់រយៈពេលចំនួន ១២ ខែ នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រវ៉ាន់ដា ក្នុងមុខតំណែងជាអ្នកវិភាគ/អ្នកស៊ើបអង្កេត និងបានចំណាយពេល១២ខែ នៅតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន ដែលនៅទីនោះគាត់ជាប្រធានអង្គភាពស៊ើបការណ៍សម្ងាត់។ គាត់ក៏ធ្លាប់ធ្វើជាអ្នកស៊ើបអង្កេតជាន់ខ្ពស់នៅគណៈកម្មការស៊ើបអង្កេតពិសេស និងឯករាជ្យសម្រាប់ទីម័រខាងកើតរបស់ អ.ស.ប ក្នុងឆ្នាំ ២០០៦ (U.N Independent Special Commission of Inquiry for Timore Leste) និងជាអ្នកទទួលខុសត្រូវចំពោះការបង្កើតអង្គភាពស៊ើបការណ៍សម្ងាត់នៅ អ.វ.ត.ក ក្នុងឆ្នាំ ២០០៧។ គាត់បានវិលត្រឡប់មក អ.វ.ត.ក ក្នុងឆ្នាំ ២០០៨ និងបានបម្រើការងារជាប្រធានអង្គភាពស៊ើបការណ៍សម្ងាត់ និងវិភាគ។

បន្ទុក"[11]។ យោងតាមការរំឭករបស់លោក Bastin អ្នកជំនាញដែលមានរហស្សនាម TCE-33 បានស្ថិតនៅស្ងៀម ហើយពុំតវ៉ាអ្វីឡើយ[12]។

៦. កាលពីថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ មេធាវីការពារក្តីបានដាក់សំណើមួយទៅ ក.ស.ច.ស ដោយបានស្នើសុំព័ត៌មានអំពីការងារកាលពីពេលកន្លងទៅរបស់ អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយ ក.ស.ព រួមទាំងកាលបរិច្ឆេទ និងលក្ខណៈនៃការងាររបស់គាត់ ដែលមេធាវីការពារក្តីពុំបានដឹងកាលពីពេលនោះ[13]។ ក.ស.ច.ស បានត្រឹមតែឆ្លើយតបថាអ្នកជំនាញដែលមានរហស្សនាម TCE-33 ត្រូវបាន ក.ស.ព ជួលឱ្យបម្រើការងារពីខែ កក្កដា ដល់ខែ ធ្នូ ឆ្នាំ ២០០៦ ប៉ុន្តែ ក.ស.ច.ស ពុំបានផ្តល់ព័ត៌មានណាមួយអំពីវិសាលភាពនៃភារកិច្ចរបស់ អ្នកជំនាញដែលមានរហស្សនាម TCE-33 នៅ ក.ស.ព ឡើយ[14]។ អ្នកជំនាញដែលមានរហស្សនាម TCE-33 បានខកខានពុំបានផ្តល់ព័ត៌មានតបទៅនឹងសំណើរបស់ មេធាវីការពារក្តីឡើយ។

៧. កាលពីថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ មេធាវីការពារក្តីជាថ្មីម្តងទៀត បានដាក់សំណើមួយទៅ ក.ស.ច.ស ដោយបានស្នើសុំព័ត៌មានអំពីអ្នកជំនាញដែលមានរហស្សនាម TCE-33។ មេធាវីការពារក្តីបានទទួលព័ត៌មានថា អ្នកជំនាញដែលមានរហស្សនាម TCE-33 បានហៅខ្លួនគាត់នៅក្នុងសំណើសៀវភៅមួយក្បាលថាគាត់បានស្រាវជ្រាវអំពីបក្សកុម្មុយនីស្តកម្ពុជា អស់រយៈពេលចំនួន ៣០ ឆ្នាំ ក្នុងមុខងារជា "អ្នកសារព័ត៌មាន, ភ្នាក់ងារស៊ើបការណ៍សម្ងាត់, អ្នកតស៊ូមតិសិទ្ធិមនុស្ស, ប្រវត្តិវិទូ, មន្ត្រីអង្គការសហប្រជាជាតិ, អ្នកស្រាវជ្រាវផ្នែកច្បាប់ និងអ្នកវិទ្យាសាស្ត្រ នយោបាយ" មុនពេលគាត់បានចូលបម្រើការងារជាអ្នកស៊ើបអង្កេតនៅ ក.ស.ច.ស[15]។ មេធាវីការពារក្តីបានស្នើសុំព័ត៌មានអំពីតួនាទីពិតប្រាកដ និងសកម្មភាពនានារបស់អ្នកជំនាញដែលមានរហស្សនាម

---

[11] សំណើរបស់ អៀង សារី សុំប្តឹងជំទាស់ចៅក្រមស៊ើបអង្កេត Marcel Lemonde និងសំណើសុំឱ្យមានសវនាការជាសាធារណៈ, ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៩, ឧបសម្ព័ន្ធ ក, ទំព័រ ១។

[12] *ដូចឯកសារយោងខាងលើ,* ទំព័រ ២។

[13] សំណើសុំព័ត៌មានទាក់ទងនឹងផលប្រយោជន៍ដ៏មានសក្តានុពល, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨, ឯកសារ A121។

[14] លិខិតរបស់ ក.ស.ច.ស កាលពីឆ្នាំ ២០០៨ ផ្ញើទៅមេធាវីការពារក្តី។

[15] សំណើសុំព័ត៌មានទាក់ទងនឹងអត្ថិភាពដ៏មានឥទ្ធិពលនៃទំនាស់ផលប្រយោជន៍នៃអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត Stephen Heder, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩, ឯកសារ A252, កថាខណ្ឌ ១ (សេចក្តីគូសបញ្ជាក់បន្ថែម)។ មេធាវីការពារក្តីកត់សម្គាល់ឃើញថា Ben Kiernan ក៏ហៅអ្នកជំនាញដែលមានរហស្សនាម TCE-33 ថាជា "អតីតមន្ត្រីស៊ើបការណ៍សម្ងាត់" ផងដែរនៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា អំពើប្រល័យពូជសាសន៍ និងការតស៊ូនៅអាស៊ីអាគ្នេយ៍៖យុត្តិធម៌នៅកម្ពុជា និងទីម័រខាងកើត 225 (Transaction Publishers 2008)។

TCE-33 ដែលគាត់បានអនុវត្តកាលពីពេលគាត់បានបម្រើការងារ ជាភ្នាក់ងារស៊ើបការណ៍សម្ងាត់ ដែលទំនងជាអាចជឿបានថាគាត់បានធ្វើការងារឲ្យសេអ៊ីអា"។ រយៈពេលចំនួន ៤ ខែ ក្រោយមក ក.ស.ច.ស បានគូសបញ្ជាក់ថាខ្លួនពុំដឹងអំពីព័ត៌មាន ឬឯកសារណាមួយដែលអាចគាំទ្រការចោទប្រកាន់នានាដែលមាននៅក្នុងសំណើរបស់មេធាវីការពារក្ដីឡើយ[16]។ ជាថ្មីម្ដងទៀត អ្នកជំនាញដែលមានរហស្សនាម TCE-33 បានខកខានពុំបានផ្ដល់ព័ត៌មានតបទៅនឹងសំណើរបស់ មេធាវីការពារក្ដីឡើយ។

៨. ចាប់តាំងពីគាត់បានចាកចេញពី ក.ស.ច.ស[17] អ្នកជំនាញដែលមានរហស្សនាម TCE-33 បានសរសេរអត្ថបទនានាទាក់ទងផ្ទាល់ទៅនឹងបញ្ហាអង្គហេតុទាំងប៉ុន្មានដែល អ.ជ.ស.ដ នឹងសម្រេចក្នុងសំណុំរឿង០០២/០១[18] និងសមត្ថភាពរបស់ អ.វ.ត.ក ក្នុងការស៊ើបអង្កេត និងការជំនុំជម្រះលើសំណុំរឿង ០០៣ និងសំណុំរឿង ០០៤[19]។

---

[16] លិខិតរបស់ ក.ស.ច.ស ទៅមេធាវីការពារក្ដីដែលមានចំណងជើងថា សំណើសុំផ្ដល់ព័ត៌មានទាក់ទិននឹងលោក Stephen Heder, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៩, ឯកសារ A252/2, ទំព័រ ២។

[17] វាហាក់ដូចជាថាអ្នកជំនាញដែលមានរហស្សនាម TCE-33 បានចាកចេញពី ក.ស.ច.ស ដោយសារគាត់ពុំមានសង្ឃឹមថាសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ នឹងពុំត្រូវបានបន្ត។ *សូមមើល កិច្ចគាំពារឯករាជ្យភាពតុលាការក្នុងតុលាការចម្រុះ៖ មេរៀនពី អ.វ.ត.ក និងទម្លាប់អនុវត្តន៍ប្រពៃបំផុតសម្រាប់ថ្ងៃអនាគត,* របាយការណ៍របស់គណៈមេធាវីអន្តរជាតិ, ខែ កញ្ញា ឆ្នាំ ២០១១, ដែលបានដកស្រង់លិខិតលាលែងពីមុខតំណែងរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ដែលបានផ្ញើទៅ ក.ស.ច.ស៖ "ដោយបានឃើញសេចក្ដីសម្រេចរបស់ចៅក្រមដើម្បីបិទកិច្ចស៊ើបសួរលើសំណុំរឿង ០០៣ ប្រកបដោយប្រសិទ្ធភាព ដោយពុំមានការស៊ើបអង្កេតក្នុងសំណុំរឿងនេះ ដែលខ្ញុំក៏ដូចជាបុគ្គលដទៃទៀតជឿថាពុំមានភាពសមហេតុផល, ដោយបានឃើញអំពីការខ្វះទំនុកចិត្តកាន់តែខ្លាំងឡើងយ៉ាងច្បាស់ក្រឡែតរបស់មន្ត្រីបុគ្គលិក អ.ស.ប រួមទាំងរូបខ្ញុំផង ចំពោះភាពជាអ្នកដឹកនាំរបស់លោក និងដោយបានឃើញអំពីបរិយាកាសអាប់អួរនៃការមិនទុកចិត្តគ្នាដែលបណ្ដាលមកពីការគ្រប់គ្រងរបស់លោកទៅលើអ្វីដែលនៅពេលបច្ចុប្បន្ននេះជាការិយាល័យដែលលែងបំពេញមុខងារបែបវិជ្ជាជីវៈ ខ្ញុំបានសន្និដ្ឋានថាពុំមានផលប្រយោជន៍ណាមួយដែលអាច ឬនឹងអាចត្រូវបានធ្វើដោយសារការងារពិគ្រោះយោបល់របស់ខ្ញុំឡើយ"។

[18] Stephen Heder, *គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីវណ្ណៈ និងខ្មាំងក្នុងជួរប្រជាជន និងជួរបដិវត្តន៍, ឆ្នាំ ១៩៦០-១៩៧៩៖ មជ្ឈិមបក្ស ស្រុក និងមូលដ្ឋាន,* ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២, *ដែលមាននៅលើគេហទំព័រ* http://www.cambodiatribunal.org/sites/default/files/reports/Heder,%20CPK%20Policy%20on%Class%20and%20Enemies,%20120426.pdf ។

[19] Stephen Heder, *យុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពាក់ព័ន្ធនឹង "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ផ្សេងៗនៃរបបខ្មែរក្រហម ចំពោះឧក្រិដ្ឋកម្មក្នុងអំឡុងសម័យខ្មែរក្រហម៖ ប្រវត្តិ និងការវិវឌ្ឍន៍នាពេលថ្មីៗ,* ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២, *ដែលមាននៅលើគេហទំព័រ* http://www.cambodiatribunal.org/sites/default/files/reports/Heder,%20CPK%20Policy%20on%20Class%20and%20Enemies,%20120426.pdf ។

៩. ក្នុងអត្ថបទមួយដែលមានចំណងជើងថា *យុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពាក់ព័ន្ធនឹង "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ផ្សេងៗនៃរបបខ្មែរក្រហម ចំពោះឧក្រិដ្ឋកម្មក្នុងអំឡុងសម័យខ្មែរក្រហម៖ ប្រវត្តិ និងការវិវឌ្ឍន៍នាពេលថ្មីៗ* (*The Personal Jurisdiction of the Extraordinary Chambers in the Courts of Cambodia as Regards Khmer Rouge "Senior Leaders" and Others " Most Responsible" for Khmer Rouge Crimes: A History and Recent Developments"*) អ្នកជំនាញដែលមានរហស្សនាម TCE-33 បានសង្ខេបយ៉ាងវែងអន្លាយអំពីការចរចាដើម្បីបង្កើត អ.វ.ត.ក និងបានសន្និដ្ឋានថា "បរិយាយតាមទិដ្ឋភាពច្បាប់ ការបកស្រាយសមហេតុផលបំផុត" អំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក គឺថាវាគួរតែរួមបញ្ចូលទាំងមេដឹកនាំបក្សកុម្មុយនីស្តថ្នាក់កណ្តាល[20]។ អត្ថបទនេះត្រូវបានសរសេរឡើងស្របពេលដែល ក.ស.ច.ស កំពុងពិចារណាថាតើ អ.វ.ត.ក មានយុត្តាធិការដើម្បីស៊ើបអង្កេតជនសង្ស័យក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ និងការលាលែងពីមុខតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Laurent Kasper Ansermet ដោយសារគាត់គ្មានសមត្ថភាពដើម្បីបំពេញភារកិច្ច[21]។

១០. នាពេលបច្ចុប្បន្ន អ្នកជំនាញដែលមានរហស្សនាម TCE-33 គឺជាទីប្រឹក្សានៃមជ្ឈមណ្ឌលឯកសារកម្ពុជា[22] ដែលជាអង្គការដែលមានចំណាប់អារម្មណ៍យ៉ាងខ្លាំង និងគិតទុកជាមុន ក្នុងការមើលឃើញការផ្តន្ទាទោសក្នុងសំណុំរឿង០០២[23]។ អ្នកជំនាញដែលមានរហស្សនាម TCE-33 ក៏ត្រូវបានរាយការណ៍ថាគាត់កំពុងបម្រើការងារជូនអង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Right Watch) ក្នុងតួនាទីស្រាវជ្រាវ។

## II. ព័ត៌មានដែលមេធាវីការពារក្តីបានស្នើសុំ

[20] *ដូចឯកសារយោងខាងលើ* ទំព័រ ៤២។

[21] *សូមមើល* សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង, ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១២, សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង, ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២, សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២, ដែលបញ្ជាក់អំពីការលាលែងពីមុខតំណែងរបស់គាត់ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១២។

[22] *សូមមើល* តារាងចាត់តាំងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានបង្ហាញថាអ្នកជំនាញដែលមានរហស្សនាម TCE-33 ជាទីប្រឹក្សា *ដែលមាននៅលើគេហទំព័រ* http://d.ccam.org/Abouts/Staff/pdf/DC-Cam_CHART_2012.pdf ។

[23] *សូមមើល* សេចក្តីសង្កេតរួមរបស់លោក អៀង សារី ស្តីពីសាក្សី និងអ្នកជំនាញមួយចំនួនដែលសហព្រះរាជអាជ្ញា, ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី នួន ជា បានស្នើសុំកោះហៅបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញបញ្ជីឈ្មោះសាក្សីបណ្តោះអាសន្ន, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ E93/12, កថាខណ្ឌ ៩។

១១. មេធាវីការពារក្តីសូមគោរពស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ស្វែងរកព័ត៌មានពាក់ព័ន្ធនឹង៖

**ការងាររបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយ ក.ស.ព**

ក. ថាតើការងារមុនរបស់ អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយសេអ៊ីអា ឬភ្នាក់ងារស៊ើបការណ៍សម្ងាត់ណាមួយផ្សេងទៀត ត្រូវបានបង្ហើបឲ្យ ក.ស.ព បានដឹងមុនពេលគាត់ចាប់ផ្តើមបំពេញការងាររបស់គាត់ដែរ ឬយ៉ាងណា

ខ. លក្ខណៈពិតប្រាកដនៃការងាររបស់ អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយ ក.ស.ព ហើយថាតើ៖

i. អ្នកជំនាញដែលមានរហស្សនាម TCE-33 បានចូលរួមក្នុងឋានៈណាមួយនៅក្នុងដំណើរការស៊ើបអង្កេត20121207_TrialDay135_HunChhunLy[Day2]-Draft

ឬការតាក់តែងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែរឬទេ ដូចជា៖

១. ការពិនិត្យមើលឯកសារឡើងវិញ និងការវិភាគឯកសារ

២. ការស្តាប់ចម្លើយសាក្សី ឬ

៣. ការចូលរួមក្នុងការបំផុសគំនិតជាមួយសមាជិក ក.ស.ព

គ. ឈ្មោះរបស់មន្ត្រីបុគ្គលិក ក.ស.ព ទាំងអស់ដូចជាលោក Craig Etcheson ជាដើម ដែលអ្នកជំនាញដែលមានរហស្សនាម TCE-33 ធ្លាប់មានទំនាក់ទំនង ចាប់តាំងពីគាត់បានចាកចេញពី អ.វ.ត.ក និងកាលបរិច្ឆេទ និងលក្ខណៈនៃទំនាក់ទំនងនោះ។

**ការងាររបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយ ក.ស.ច.ស**

ឃ. ថាតើការងារមុនរបស់ អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយសេអ៊ីអា ឬភ្នាក់ងារស៊ើបការណ៍សម្ងាត់ណាមួយផ្សេងទៀតត្រូវបានបង្ហើបឲ្យ ក.ស.ច.ស បានដឹងមុនពេលគាត់បានចាប់ផ្តើមបម្រើការងារដែរ ឬយ៉ាងណា។

ង. លក្ខណៈពិតប្រាកដនៃការងាររបស់ អ្នកជំនាញដែលមានរហស្សនាម TCE-33 នៅ ក.ស.ច.ស រួមទាំងថាតើ៖

i. អ្នកជំនាញដែលមានរហស្សនាម TCE-33 បានចូលរួមក្នុងឋានៈណាក៏ដោយនៅក្នុងដំណើរការស៊ើបសួរ ឬការតាក់តែងដីកាដំណោះស្រាយដែរឬទេ ដូចជា៖

១. ការពិនិត្យមើលឯកសារឡើងវិញ និងការវិភាគឯកសារ

២. ការស្តាប់ចម្លើយសាក្សី ឬ

៣. ការចូលរួមក្នុងការបំផុសគំនិត ជាមួយសមាជិក ក.ស.ច.ស

ច. កាលបរិច្ឆេទដែលអ្នកជំនាញដែលមានរហស្សនាម TCE-33 បានឈប់បម្រើការងារជាអ្នកស៊ើបអង្កេត, អ្នកពិគ្រោះយោបល់, ឬក្នុងឋានៈណាមួយផ្សេងទៀតសម្រាប់ ក.ស.ច.ស។

ឆ. ឈ្មោះរបស់មន្ត្រីបុគ្គលិកទាំងអស់នៅ ក.ស.ច.ស ដូចជាលោក David Boyle ជាដើម ដែលអ្នកជំនាញដែលមានរហស្សនាម TCE-33 ធ្លាប់មានទំនាក់ទំនងជាមួយ ចាប់តាំងពីគាត់បានចាកចេញពី អ.វ.ត.ក និងកាលបរិច្ឆេទ និងលក្ខណៈនៃទំនាក់ទំនងនោះ។

**ការងាររបស់ អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយការិយាល័យផ្សេងៗនៅ អ.វ.ត.ក**

ជ. ថាតើអ្នកជំនាញដែលមានរហស្សនាម TCE-33 បានបម្រើការងារជាអ្នកពិគ្រោះយោបល់ ឬក្នុងឋានៈណាមួយផ្សេង នៅការិយាល័យណាមួយនៃ អ.វ.ត.ក។

ឈ. ប្រសិនបើដូច្នេះ ថាតើការងារមុនរបស់ អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយសេអ៊ីអា ឬទីភ្នាក់ងារស៊ើបការណ៍សម្ងាត់ផ្សេងៗ ត្រូវបានបង្ហើបឲ្យការិយាល័យនោះបានដឹង នៅមុនពេលគាត់បានចាប់ផ្ដើមបម្រើការងាររបស់គាត់ដែរ ឬយ៉ាងណា។

ញ. លក្ខណៈពិតប្រាកដនៃការងាររបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយអង្គភាពនោះ រួមទាំងថាតើអ្នកជំនាញដែលមានរហស្សនាម TCE-33 បានចូលរួមក្នុង៖

- i. ការពិនិត្យមើលឯកសារឡើងវិញ និងការវិភាគឯកសារ
- ii. ការស្ដាប់ចម្លើយសាក្សី ឬ
- iii. ការចូលរួមក្នុងការបំផុសគំនិត

ដ. កាលបរិច្ឆេទនៃការងាររបស់ អ្នកជំនាញដែលមានរហស្សនាម TCE-33

**ឯកសារបោះពុម្ពផ្សាយក្រោយខែ កុម្ភៈ ឆ្នាំ ២០១០ របស់អ្នកជំនាញដែលមានរហស្សនាម TCE-33**

ឋ. ចំណងជើង កាលបរិច្ឆេទ និងការបោះពុម្ពផ្សាយសៀវភៅ, អត្ថបទ ឬឯកសារនានាទាក់ទងនឹង អ.វ.ត.ក និង/ឬ សំណុំរឿង ០០២ ដែល អ្នកជំនាញដែលមានរហស្សនាម TCE-33 បានបោះពុម្ពផ្សាយ ចាប់តាំងពីគាត់បានចាកចេញពីការងារនៅ អ.វ.ត.ក។

ឌ. ថាតើ អ្នកជំនាញដែលមានរហស្សនាម TCE-33 បានពិភាក្សាអំពីអត្ថបទរបស់គាត់ដែលបានបោះពុម្ពផ្សាយកាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២[24] ជាមួយសមាជិកណាខ្លះនៃ ក.ស.ច.ស (រួមទាំងចៅក្រម) ឬ ក.ស.ព មុនពេល ឬក្នុងអំឡុងពេលគាត់កំពុងសរសេរអត្ថបទនេះ ឬក្រោយពេលគាត់បានបោះពុម្ពផ្សាយអត្ថបទនេះ ហើយប្រសិនបើដូច្នេះ សូមបញ្ជាក់អំពី៖

i. កាលបរិច្ឆេទ, ភាពញឹកញាប់ និងខ្លឹមសារនៃទំនាក់ទំនងទាំងនោះ
ii. ថាតើអ្នកជំនាញដែលមានរហស្សនាម TCE-33 បានដាក់បញ្ចូលខ្លឹមសារណាមួយនៃទំនាក់ទំនងទាំងនោះទៅក្នុងអត្ថបទរបស់គាត់ដែរឬយ៉ាងណា ហើយប្រសិនបើដូច្នេះ គាត់ដាក់បញ្ចូលក្នុងបរិបទអ្វី ហើយ
iii. ថាតើអ្នកជំនាញដែលមានរហស្សនាម TCE-33 បានប្រគល់សំណៅថតចម្លងនៃអត្ថបទនោះទៅសមាជិកណាខ្លះនៃ ក.ស.ច.ស (រួមទាំងចៅក្រម)ឬ ក.ស.ព។

ឍ. ថាតើអ្នកជំនាញដែលមានរហស្សនាម TCE-33 បានធ្វើសម្ភាសន៍មន្ត្រីបុគ្គលិកនៃ អ.វ.ត.ក ឬបុគ្គលដទៃទៀត នៅពេលគាត់កំពុងសរសេរអត្ថបទដែលត្រូវបានបោះពុម្ពផ្សាយកាលពីថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១២ ដែរឬយ៉ាងណា ហើយប្រសិនបើដូច្នេះ៖

i. ឈ្មោះរបស់មន្ត្រីបុគ្គលិក ឬបុគ្គលិកដទៃទៀត ដែលគាត់បានធ្វើសម្ភាសន៍។
ii. កាលបរិច្ឆេទនៃកិច្ចសម្ភាសន៍ និង
iii. ខ្លឹមសារនៃកិច្ចសម្ភាសន៍ទាំងនេះ

ណ. ថាតើអ្នកជំនាញដែលមានរហស្សនាម TCE-33 បានពិភាក្សាអំពីសៀវភៅ, អត្ថបទ ឬឯកសារផ្សេងៗ ជាមួយសមាជិកណាខ្លះនៃ ក.ស.ច.ស (រួមទាំងចៅក្រម) ឬ

---

[24] *យុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពាក់ព័ន្ធនឹង "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ផ្សេងៗនៃ របបខ្មែរក្រហម ចំពោះឧក្រិដ្ឋកម្មក្នុងអំឡុងសម័យខ្មែរក្រហម៖ ប្រវត្តិ និងការវិវឌ្ឍន៍នាពេលថ្មីៗ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីវណ្ណៈ និងខ្មាំងក្នុងជួរប្រជាជន និងជួរបដិវត្តន៍, ឆ្នាំ ១៩៦០-១៩៧៩៖ មជ្ឈិម បក្ស ស្រុក និងមូលដ្ឋាន,* (*The Personal Jurisdiction of the Extraordinary Chambers in the Courts of Cambodia as Regards Khmer Rouge "Senior Leaders" and Others " Most Responsible" for Khmer Rouge Crimes: A History and Recent Developments and Communist Party of Kampuchea Policies on Class and on Dealing with Enemies Among the People and Within the Revolutionary Ranks, 1960-1979: Centre, Districts and Grassroots")*។ *សូមមើល ជើងទំព័រលេខ* 18-19 ខាងលើ។

ក.ស.ព ហើយប្រសិនបើដូច្នេះសូមបញ្ជាក់អំពី កាលបរិច្ឆេទ, ភាពញឹកញាប់ និងខ្លឹមសារនៃការពិភាក្សាទាំងនោះ។

**ឯកសារប្រភពដើមរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33**

ទ. ថាតើអ្នកជំនាញដែលមានរហស្សនាម TCE-33 មានឯកសារប្រភពដើមណាខ្លះដែលពុំទាន់មានក្នុងសំណុំរឿង ហើយប្រសិនបើដូច្នេះ សូមបញ្ជាក់អំពី៖

i. ប្រភេទនៃឯកសារដែលគាត់មាន

ii. ចំណងជើង, ថ្ងៃបរិច្ឆេទ និងព័ត៌មានអំពីការបោះពុម្ពផ្សាយទាក់ទងនឹងឯកសារទាំងនោះ និង

iii. ខ្លឹមសារនៃឯកសារទាំងនោះ។

**ទំនាក់ទំនងរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗ**

ធ. ថាតើ អ្នកជំនាញដែលមានរហស្សនាម TCE-33 ធ្លាប់មានទំនាក់ទំនងជាមួយសាក្សី (អ្នកជំនាញ ឬផ្សេងពីនេះ) ឬដើមបណ្តឹងរដ្ឋប្បវេណីដែលធ្លាប់បានផ្តល់សក្ខីកម្ម ឬដែលគ្រោងផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ហើយប្រសិនបើដូច្នេះ សូមបញ្ជាក់អំពីកាលបរិច្ឆេទ, ភាពញឹកញាប់ និងខ្លឹមសារនៃទំនាក់ទំនងទាំងនោះ។

**ការងាររបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា**

ន. មុខងារ និងភារកិច្ចរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ក្នុងអំឡុងពេលដែលគាត់បានមានទំនាក់ទំនងជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា

ប. វិសាលភាពនៃទំនាក់ទំនងរបស់ អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីពេលកន្លងទៅ រួមទាំង៖

i. កាលបរិច្ឆេទដែលអ្នកជំនាញដែលមានរហស្សនាម TCE-33 បានធ្វើការងារជាមួយ ឬបានបម្រើការងារជូនមជ្ឈមណ្ឌលឯកសារកម្ពុជា និង

ii. តួនាទីរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ក្នុងការធ្វើការងារជាមួយ ឬ ក្នុងការបម្រើការងារជូនមជ្ឈមណ្ឌលឯកសារកម្ពុជា

iii. ឯកសារដែលបានផលិតដែលជាលទ្ធផលនៃការងារនោះ

**ការងាររបស់ អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយអង្គការឃ្លាំមើលសិទ្ធិមនុស្ស**

ផ. មុខងាររបស់ អ្នកជំនាញដែលមានរហស្សនាម TCE-33 ក្នុងអំឡុងពេលដែលគាត់បានមានទំនាក់ទំនងជាមួយអង្គការឃ្លាំមើលសិទ្ធិមនុស្ស ឬក្នុងអំឡុងពេលដែលគាត់ត្រូវបានអង្គការនេះជួលឱ្យបម្រើការងារ

ព. វិសាលភាពនៃទំនាក់ទំនងរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយអង្គការឃ្លាំមើលសិទ្ធិមនុស្សកាលពីពេលកន្លងទៅ រួមទាំង៖

i. កាលបរិច្ឆេទដែល អ្នកជំនាញដែលមានរហស្សនាម TCE-33 បានធ្វើការងារជាមួយ ឬបានបម្រើការងារជូនអង្គការឃ្លាំមើលសិទ្ធិមនុស្ស

ii. ឋានៈរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ដែលបានធ្វើការងារជាមួយ ឬបានបម្រើការងារជូនអង្គការឃ្លាំមើលសិទ្ធិមនុស្ស

iii. ឯកសារដែលត្រូវបានផលិតដែលជាលទ្ធផលនៃការងារនោះ

ភ. ថាតើអ្នកជំនាញដែលមានរហស្សនាម TCE-33 បានបញ្ចេញព័ត៌មានណាមួយឱ្យអង្គការឃ្លាំមើលសិទ្ធិមនុស្ស ឬអង្គការផ្សេងៗបានដឹង ទាក់ទងនឹងសំណុំរឿង ០០៣ ឬ ០០៤ មុនពេលគាត់បានចាកចេញពី អ.វ.ត.ក ឬបន្ទាប់ពីគាត់បានចាកចេញ (មានរបាយការណ៍ថាព័ត៌មានបានលេចឮដល់ប្រព័ន្ធផ្សព្វផ្សាយ ដែលមានតែមន្ត្រីបុគ្គលិកនៅ អ.វ.ត.ក ដូចជាអ្នកជំនាញដែលមានរហស្សនាម TCE-33 ប៉ុណ្ណោះ ដែលបានដឹង)។

**ការងាររបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយសេអ៊ីអា ឬទីភ្នាក់ងារស៊ើបការណ៍សម្ងាត់ផ្សេងៗរបស់សហរដ្ឋអាមេរិក**

ម. ការងារមុនរបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមន្ត្រីស៊ើបការណ៍សម្ងាត់ ឬក្នុងឋានៈផ្សេងទៀត ជាមួយសេអ៊ីអា ឬទីភ្នាក់ងារស៊ើបការណ៍សម្ងាត់ណាមួយរបស់សហរដ្ឋអាមេរិក រួមទាំង៖

i. កាលបរិច្ឆេទជាក់លាក់នៃការងាររបស់គាត់

ii. តួនាទីជាក់លាក់របស់គាត់នៅក្នុងទីភ្នាក់ងារនេះ

iii. សកម្មភាពដែល អ្នកជំនាញដែលមានរហស្សនាម TCE-33 បានអនុវត្តក្នុងអំឡុងពេលដែលគាត់បានស្ថិតនៅក្នុងមុខតំណែងនេះ និង

iv. អ្វីផ្សេងទៀតដែលអាចពាក់ព័ន្ធនឹងបញ្ហានៃសមត្ថភាពរបស់ អ្នកជំនាញដែលមានរហស្សនាម TCE-33 ដើម្បីធ្វើជាសាក្សីប្រកបដោយឯករាជ្យ និងពុំលម្អៀង។

## III. ឧទ្ធរណ៍

១២. ប្រវត្តិការងាររបស់ អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយ អ.វ.ត.ក និងសកម្មភាពវិជ្ជាជីវៈរបស់គាត់ នាំឲ្យមានការសន្និដ្ឋានដោយមិនអាចប្រកែកបានថា អ្នកជំនាញដែលមានរហស្សនាម TCE-33 ពុំអាចជាសាក្សីដែលពុំលម្អៀងឡើយ។ ជាបឋម បន្ទាប់ពីគាត់បានសរសេររបាយការណ៍មួយដែលក្នុងនោះគាត់បានស៊ើបអង្កេតលោក អៀង សារី និងជនជាប់ចោទដទៃទៀត និងបានកំណត់អត្តសញ្ញាណពួកគាត់ថាជា "បេក្ខជនសម្រាប់ការចោទប្រកាន់"[25] អ្នកជំនាញដែលមានរហស្សនាម TCE-33 បានទៅបម្រើការងារជាអ្នកវិភាគសម្រាប់ ក.ស.ព ដែលជាអង្គភាពមួយដែលបានស៊ើបអង្កេតបុគ្គលដដែលទាំងនេះ និងបានរៀបចំការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌប្រឆាំងនឹងពួកគាត់។ បន្ទាប់មកទៀត អ្នកជំនាញដែលមានរហស្សនាម TCE-33 បានផ្លាស់ទៅ ក.ស.ច.ស ដែលមានភារកិច្ចប្រមែប្រមូលភស្តុតាងដោះបន្ទុក និងដាក់បន្ទុក ដោយមិនលម្អៀង[26] ដើម្បីបំពេញមុខងារជាអ្នកស៊ើបអង្កេត ដែលតាមរយៈនេះបានធ្វើឲ្យអ្នកជំនាញដែលមានរហស្សនាម TCE-33 មានលទ្ធភាពផ្តល់សុពលភាពបន្ថែមទៀតចំពោះសេចក្តីសន្និដ្ឋានមុនៗរបស់គាត់ពាក់ព័ន្ធនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ។ យោងទៅតាមសកម្មភាពមុនៗរបស់គាត់ដែលតម្រង់ទៅរកការចោទប្រកាន់ ការបម្រើការងាររបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ជូន ក.ស.ច.ស គឺជាទំនាស់ផលប្រយោជន៍ពីធម្មជាតិ។

១៣. អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ច ដើម្បីធានាបាននូវកិច្ចដំណើរការនីតិវិធីប្រកបដោយភាពត្រឹមត្រូវ និងតម្លាភាព និងដើម្បីការពារផលប្រយោជន៍របស់លោក អៀង សារី[27]។ ប្រវត្តិការងាររបស់អ្នកជំនាញដែលមានរហស្សនាម TCE-33 ជាមួយ អ.វ.ត.ក ការងារដែលត្រូវបានជឿថាជាមន្ត្រីស៊ើបការណ៍សម្ងាត់របស់សេអ៊ីអា នៅពេលមួយពាក់ព័ន្ធនឹងជីកាដំណោះស្រាយ និងសកម្មភាពវិជ្ជាជីវៈផ្សេងៗរបស់គាត់ គឺមានភាពពាក់ព័ន្ធទៅនឹងការសម្រេចថាតើអ្នកជំនាញដែលមានរហស្សនាម TCE-33 អាចផ្តល់សក្ខីកម្មប្រកបដោយឯករាជ្យ និងពុំលម្អៀងដែរ ឬយ៉ាងណា។

---

[25] *សូមមើល* Stephen Heder & Brian Tittemore, បេក្ខជនចំនួន ៧ រូបសម្រាប់ការចោទប្រកាន់៖ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហម (Seven Candidates for Prosecution: Accountability for the Crimes of the Khmer Rouge), ទំព័រ ៥៩-១០០, ឯកសារ E3/48, ដែលអ្នកជំនាញដែលមានរហស្សនាម TCE-33 ជាសំខាន់បានពន្យល់ ក.ស.ព អំពីការចោទប្រកាន់លោក អៀង សារី, លោក នួន ជា និងលោក ខៀវ សំផន រួមទាំងការផ្តល់ "ការវិភាគ និងការ សន្និដ្ឋានតាមទិដ្ឋភាពច្បាប់" ពាក់ព័ន្ធនឹងការចោទប្រកាន់ដែលត្រូវបានស្នើឡើងចំពោះជនជាប់ចោទម្នាក់ៗ។

[26] វិធាន ៥៥(២),៥៥(៥)។

[27] វិធាន ២១(១), ២១(១)(ក)។

១៤. មេធាវីការពារក្ដីមានព័ត៌មានបន្តិចបន្តួចទាក់ទងនឹងលក្ខណៈនៃប្រវត្តិ និងសកម្មភាពវិជ្ជាជីវៈ របស់អ្នកជំនាញដែលមានរហស្សនាម TCE-33។ យ៉ាងណាមិញ ព័ត៌មានដែលមេធាវីការពារក្ដីមានបង្ហាញច្បាស់ថា អ្នកជំនាញដែលមានរហស្សនាម TCE-33 បានវិនិច្ឆ័យទុកជាមុនអំពីសំណុំរឿងនេះ និងបានសម្រេចទុកជាមុនអំពីពិរុទ្ធភាពរបស់លោក អៀង សារី។ ដើម្បីសម្រេចថាតើអ្នកជំនាញដែលមានរហស្សនាម TCE-33 អាចជាសាក្សីប្រកបដោយឯករាជ្យ និងពុំលម្អៀងដែរឬយ៉ាងណា មេធាវីការពារក្ដីត្រូវតែដឹងឲ្យបានពេញលេញអំពីប្រវត្តិ និងសកម្មភាពវិជ្ជាជីវៈរបស់គាត់នៅមុនពេលគាត់ផ្ដល់សក្ខីកម្ម។

**អាស្រ័យហេតុនេះ** មេធាវីការពារក្ដីសូមគោរពស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង អនុវត្តសិទ្ធិអំណាចដែលខ្លួនមាន និងបង្គាប់ឲ្យអ្នកជំនាញដែលមានរហស្សនាម TCE-33 ផ្ដល់ព័ត៌មានដូចដែលបានស្នើសុំខាងលើ ឲ្យបានឆាប់រហ័សតាមលទ្ធភាពដែលអាចធ្វើទៅបាន ប៉ុន្តែឲ្យបានមុនពេលនៃការចាប់ផ្ដើមសក្ខីកម្មរបស់គាត់។

សូមអង្គជំនុំជម្រះសាលាដំបូងទទួលនូវការគោរពអំពីយើងខ្ញុំ។

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី៧ ខែ ធ្នូ ឆ្នាំ ២០១២។